**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល**
**លេខៈ០០៤/២៤.ក្រស.. អអរ**

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ជោគជ័យដ៏គ្រចះគ្រចង់ នៃដំណើរទស្សនកិច្ចផ្លូវការរបស់ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសាធារណរដ្ឋបារាំង និងការចូលរួមវេទិកាសេដ្ឋកិច្ចពិភពលោក នៅទីក្រុងដាវ៉ូស ប្រទេសស្វីស

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**លោកជំទាវបណ្ឌិត** បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់រាជរដ្ឋាភិបាល ធ្វើមាតុភូមិនិវត្តន៍ នាវេលារសៀល ថ្ងៃទី២០ ខែមករា ឆ្នាំ២០២៤ នេះ បន្ទាប់ពីបានបំពេញទស្សនកិច្ចផ្លូវការប្រកបដោយជោគជ័យយ៉ាងគ្រចះគ្រចង់ នៅសាធារណរដ្ឋបារាំង ពីថ្ងៃទី១៨-១៩ ខែមករា ឆ្នាំ២០២៤ តបតាមការអញ្ជើញរបស់ **ឯកឧត្តម អេម៉ានុយអែល ម៉ាក្រុង** ប្រធានាធិបតី **នៃសាធារណរដ្ឋបារាំង** និងអញ្ជើញចូលរួមវេទិកាសេដ្ឋកិច្ចពិភពលោក នៅទីក្រុងដាវ៉ូស ប្រទេសស្វីស ពីថ្ងៃទី១៦-១៧ ខែមករា ឆ្នាំ២០២៤ តបតាមការអញ្ជើញរបស់ លោកសាស្ត្រាចារ្យ **Klaus Schwab** ស្ថាបនិកនិងជាប្រធានប្រតិបត្តិវេទិកាសេដ្ឋកិច្ចពិភពលោក។

### ដំណើរទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋបារាំង

<u>ក្របខ័ណ្ឌនយោបាយ និងការទូត៖</u> **សម្តេចធិបតី** និង**លោកជំទាវបណ្ឌិត** ត្រូវបានទទួលបដិសណ្ឋារកិច្ចយ៉ាងកក់ក្តៅលើកម្រាលព្រំក្រហមអមដោយកងគ្រែទំពកិត្តិយស នៅអាកាសយានដ្ឋានអន្តរជាតិ **Orly** មុននឹងទទួលការស្វាគមន៍ដោយផ្ទាល់ពី **ឯកឧត្តម អេម៉ានុយអែល ម៉ាក្រុង** ប្រធានាធិបតី នៃសាធារណរដ្ឋបារាំង នៅឯវិមានអេលីហ្សេ។ ជំនួបមេដឹកនាំកំពូលនៃប្រទេសទាំងពីរ បានប្រព្រឹត្តទៅក្នុងបរិយាកាសប្រកបដោយមនោសញ្ចេតនាស្និទ្ធស្នាលបំផុត ដោយ **សម្តេចធិបតី** និង**ឯកឧត្តមប្រធានាធិបតី** បានរម្លឹកអំពីប្រវត្តិនៃទំនាក់ទំនងជាប្រវត្តិសាស្ត្ររវាងកម្ពុជា-បារាំង និងបង្ហាញការពេញចិត្តចំពោះលទ្ធផលប្រកបដោយផ្លែផ្កានៃកិច្ចសហប្រតិបត្តិការគ្រប់វិស័យរវាងប្រទេសទាំងពីរទាំងវិស័យនយោបាយ សេដ្ឋកិច្ច វប្បធម៌ [illegible] និងអន្តរកាលថាមពល ព្រមទាំងបានឯកភាពលើកកម្ពស់ទំនាក់ទំនងក្នុងគោលដៅធ្វើឱ្យសម្រេចបាននូវ ភាពជាដៃគូយុទ្ធសាស្ត្រ ដើម្បីឱ្យទំនាក់ទំនងទ្វេភាគីកាន់តែមានភាពស៊ីជម្រៅ។

**ប្រធានាធិបតីបារាំង** បានសម្តែងការកោតសរសើរ និងវាយតម្លៃខ្ពស់ ចំពោះការរួមចំណែករបស់កម្ពុជានៅក្នុងបេសកកម្មរក្សាសន្តិភាពក្រោមឆត្រអង្គការសហប្រជាជាតិ ការប្រកាសគោលជំហរប្រឆាំងការឈ្លានពានរបស់រុស្ស៊ីលើប្រទេសអ៊ុយក្រែន ការបណ្តុះបណ្តាលជំនាញបោសសម្អាតមីនដល់ប្រទេសអ៊ុយក្រែន ការពង្រឹងពហុភាគីនិយម និងកិច្ចសហប្រតិបត្តិការជាអន្តរជាតិដើម្បីស្ថិរភាព វិបុលភាពក្នុងតំបន់ និងពិភពលោក។ ជាការកត់សម្គាល់ ភាគីបារាំង បានសន្យាបន្តផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការដល់ប្រទេសកម្ពុជា ក្នុងទំហំទឹកប្រាក់**ប្រមាណ២១៥លានអឺរ៉ូ** តាមរយៈទីភ្នាក់ងារអភិវឌ្ឍន៍បារាំង (AFD) ដើម្បីគាំទ្រដល់វិស័យបណ្តុះបណ្តាលវិជ្ជាជីវៈ ថាមពល និងផលិតកម្មទឹកស្អាត។ **នាយករដ្ឋមន្ត្រីកម្ពុជា** បានថ្លែងអំណរគុណចំពោះបដិសណ្ឋារកិច្ចប្រកបដោយភាពកក់ក្តៅ និងរាក់ទាក់បំផុតរបស់ **ឯកឧត្តមប្រធានាធិបតី** និងបានថ្លែងអំណរគុណដល់រដ្ឋាភិបាលនិងប្រជាជនបារាំងដែលតែងតែផ្តល់ការគាំទ្រដល់ប្រទេសកម្ពុជាដើម្បីស្តារ និងអភិវឌ្ឍប្រទេសឱ្យមានការរីកចម្រើនដូចសព្វថ្ងៃ។

ក្រៅពីជំនួបទ្វេភាគីជាមួយ ឯកឧត្តមប្រធានាធិបតី **សម្តេចធិបតី** ក៏ត្រូវបានទទួលការស្វាគមន៍យ៉ាងអធិកអធមនិងរាក់ទាក់កក់ក្តៅប្រកបដោយកិត្តិយសដ៏ខ្ពង់ខ្ពស់ពីសំណាក់ **ឯកឧត្តម** Gérard Larcher ប្រធានព្រឹទ្ធសភា និង **លោកជំទាវ** Yaël BRAUN-PIVET ប្រធានរដ្ឋសភា នៃសាធារណរដ្ឋបារាំង។ នៅក្នុងជំនួបសម្តែងការគួរសមទាំងនោះ ភាគីបារាំង បានចូលរួមអបអរសាទរ និងបង្ហាញសុទិដ្ឋិនិយមខ្ពស់ចំពោះ **សម្តេចធិបតី** សម្រាប់ការដឹកនាំរាជរដ្ឋាភិបាលបន្តវេន ព្រមទាំងជឿជាក់ថា ក្រោមការដឹកនាំរបស់ **សម្តេចធិបតី** ទំនាក់ទំនងកម្ពុជា-បារាំង នឹងកាន់តែទទួលបានផ្លែផ្កាថ្មីៗបន្ថែមទៀត។ **សម្តេចធិបតី** និងភាគីបារាំង ក៏បានពិភាក្សា និងផ្លាស់ប្តូរយោបល់គ្នាអំពីកិច្ចសហប្រតិបត្តិការកម្ពុជា-បារាំង ក្នុងវិស័យនយោបាយ សេដ្ឋកិច្ច វប្បធម៌ ភាសា អន្តរកាលថាមពល រួមទាំងកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌសភា។ ជាការកត់សម្គាល់ ភាគីសភាបារាំង បានបង្ហាញការគាំទ្រនូវគំនិតផ្តួចផ្តើមរបស់ **សម្តេចធិបតី** ក្នុងការបង្កើតមជ្ឈមណ្ឌលវប្បធម៌ថ្នាក់តំបន់មួយនៅក្នុងប្រទេសកម្ពុជា សម្រាប់ការបណ្តុះបណ្តាលភាសាបារាំង និងផ្សព្វផ្សាយវប្បធម៌បារាំង ដល់ប្រជាជននៃប្រទេសក្នុងតំបន់អាស៊ី។

ក្នុងកិច្ចសហប្រតិបត្តិការជាមួយក្រុមប្រទេសនិយាយភាសាបារាំង **សម្តេចធិបតី** បានទទួលជួបពិភាក្សាដាច់ដោយឡែកជាមួយ លោកជំទាវ Louise MUSHIKIWABO អគ្គលេខាធិការអង្គការអន្តរជាតិហ្វ្រង់កូហ្វូនី (Francophonie) និងលោក Geoffroy Roux De Bezieux ប្រធានសម្ព័ន្ធនិយោជកហ្វ្រង់កូហ្វូន (APF)។ **លោកជំទាវអគ្គលេខាធិការ** Francophonie បានបង្ហាញការគាំទ្រកម្ពុជាធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីនៅឆ្នាំ២០២៦ និងស្នើកម្ពុជាបន្តចូលរួមចែករំលែកបទពិសោធថែរក្សាស្ថិរភាព សន្តិភាព សេដ្ឋកិច្ច ទេសចរណ៍ និងវប្បធម៌ ដល់បណ្តាប្រទេសនិយាយភាសាបារាំង និងប្រទេសផ្សេងទៀត។ ចំណែក **ប្រធានសម្ព័ន្ធនិយោជកហ្វ្រង់កូហ្វូន** បានបង្ហាញបំណងជួយផ្សព្វផ្សាយឱកាសវិនិយោគនៅកម្ពុជា និងនៅក្នុងទ្វីបអាស៊ី ដល់បណ្តាក្រុមហ៊ុនបារាំង ជាពិសេស ស្ថិរភាព នយោបាយ ម៉ាក្រូសេដ្ឋកិច្ច និងសុខសន្តិភាពពេញលេញរបស់កម្ពុជា។ APF ក៏បានចាត់ទុកភាពជាម្ចាស់ផ្ទះ នៃកិច្ចប្រជុំកំពូលអង្គការអន្តរជាតិហ្វ្រង់កូហ្វូនីរបស់កម្ពុជា ថាជាឱកាសបង្ហាញភាពទាក់ទាញ

ដល់វិនិយោគិនបារាំង និងមកពីប្រទេសនិយាយភាសាបារាំងផងដែរ។ **សម្តេចធិបតី** បានថ្លែងអំណរគុណដៃគូទាំងពីរដែលគាំទ្រកម្ពុជារៀបចំកិច្ចប្រជុំកំពូលនៃអង្គការអន្តរជាតិហ្វ្រង់កូហ្វូនី និងបានបញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៧ នៃរដ្ឋសភា មានថ្នាក់ដឹកនាំចេះប្រើប្រាស់ភាសាបារាំងប្រមាណ ៤0% ដែលបង្ហាញថា កម្ពុជានៅតែបន្តចូលរួមយ៉ាងសកម្មក្នុងការរក្សា និងនិយាយភាសាបារាំង។ ដោយឡែក **សម្តេចធិបតី** ក៏បង្ហាញក្តីសង្ឃឹមថា ក្រុមហ៊ុនបារាំង ពិតជាមកស្វែងរកឱកាសវិនិយោគនៅកម្ពុជា ខណៈរាជរដ្ឋាភិបាលបានបន្តអនុវត្តអភិក្រមប្រាកដនិយមដើម្បីគាំទ្រការធ្វើវិនិយោគ តាមរយៈការបង្កើតបរិយាកាសវិនិយោគដ៏អំណោយផល និងការផ្តល់ដំណោះស្រាយជាក់ស្តែងដើម្បីឱ្យវិនិយោគិនធ្វើប្រតិបត្តិការវិនិយោគដោយជោគជ័យ។

<u>ក្របខ័ណ្ឌសេដ្ឋកិច្ច ពាណិជ្ជកម្ម និងវិនិយោគ</u>៖ **សម្តេចធិបតី** បានអញ្ជើញចូលរួមជាអធិបតីក្នុង **វេទិកាធុរកិច្ចបារាំង-កម្ពុជា** ដោយមានការចូលរួមពីក្រុមហ៊ុនចំនួន ១១០ ក្នុងនោះ ៨0 ក្រុមហ៊ុនមកពីប្រទេសបារាំង និង ៣0ក្រុមហ៊ុនមកពីប្រទេសកម្ពុជា។ វេទិកានេះមានគោលដៅស្វែងយល់ពីសារៈសំខាន់នៃទំនាក់ទំនងទ្វេភាគីរវាងកម្ពុជា និងបារាំង ជាពិសេសការលើកកម្ពស់កាលានុវត្តភាពធុរកិច្ច វិនិយោគ និងពាណិជ្ជកម្ម។ **សម្តេចធិបតី** ក៏បានទទួលជួបថ្នាក់ដឹកនាំក្រុមហ៊ុនបារាំងល្បីល្បាញអន្តរជាតិចំនួន ១១ក្រុមហ៊ុន ក្នុងនោះមានដូចជា ក្រុមហ៊ុន **VINCI Airports** (វិនិយោគគម្រោងសម្បទានថាមពល និងសំណង់) ក្រុមហ៊ុន **Group ACCOR** (វិនិយោគសេវាកម្មសណ្ឋាគារ) ក្រុមហ៊ុន **Alstom** (វិនិយោគទីផ្សារដឹកជញ្ជូនតាមផ្លូវដែក ការផលិតរថភ្លើងល្បឿនលឿន ផ្លូវរថភ្លើង រថភ្លើងក្រោមដី និងសេវាហេដ្ឋារចនាសម្ព័ន្ធ) និងក្រុមហ៊ុន **Électricité de France** (វិនិយោគអគ្គិសនី) ជាដើម។

ក្នុងជំនួបដាច់ដោយឡែកពីគ្នានោះ តំណាងក្រុមហ៊ុននីមួយៗ បានជម្រាប **សម្តេចធិបតី** អំពីសក្តានុពលនៃការវិនិយោគ និងដំណើរការអាជីវកម្មរបស់ខ្លួន ព្រមទាំងបានបង្ហាញបំណងពង្រីកការវិនិយោគដែលមានស្រាប់ និងសិក្សាលើគម្រោងវិនិយោគថ្មីៗបន្ថែមទៀតនៅកម្ពុជា។ ជាការឆ្លើយតប ទន្ទឹមនឹងការចូលរួមអបអរសាទរចំពោះវឌ្ឍនភាពរបស់ក្រុមហ៊ុននីមួយៗ **សម្តេចធិបតី** បានគូសបញ្ជាក់អំពីបរិយាកាសអំណោយផលរបស់កម្ពុជា រួមមានកត្តាសុខសន្តិភាព ស្ថិរភាពនយោបាយ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ប្រព័ន្ធអនុគ្រោះ និងជាពិសេសភាពអំណោយផលនៃច្បាប់ និងគោលនយោបាយនានាពាក់ព័ន្ធនឹងការវិនិយោគ។

**សម្តេចធិបតី** ក៏បានអញ្ជើញជាអធិបតីក្នុងពិធីចុះហត្ថលេខាលើឯកសារសហប្រតិបត្តិការក្នុងវិស័យឯកជនចំនួន៦ ដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ចរវាងកម្ពុជា និងប្រទេសនិយាយភាសាបារាំង ក៏ដូចជាគាំទ្រដល់ធុរកិច្ចប្រទេសនិយាយភាសាបារាំង តាមរយៈការរៀបចំជំនួបពាណិជ្ជកម្ម សន្និសីទ សិក្ខាសាលា និងព្រឹត្តិការណ៍ធុរកិច្ច។

## ការចូលរួមវេទិកាសេដ្ឋកិច្ចពិភពលោកនៅទីក្រុងដាវ៉ូស ប្រទេសស្វីស

**សម្តេចធិបតី** បានអញ្ជើញចូលរួមកិច្ចប្រជុំប្រចាំឆ្នាំលើកទី ៥៤ នៃវេទិកាសេដ្ឋកិច្ចពិភពលោក នៅថ្ងៃទី ១៦-១៧ ខែមករា ឆ្នាំ២០២៤ ក្រោមប្រធានបទ **«ការកសាងឡើងវិញនូវទំនុកចិត្ត»** ដោយផ្តោតលើគោលការណ៍ជាមូលដ្ឋានដែលជំរុញឱ្យមានទំនុកចិត្ត រួមទាំងកត្តាតម្លាភាព សង្គតិភាព និងគណនេយ្យភាព។ ក្នុងសុន្ទរកថាគន្លឹះថ្លែងនាឱកាសនោះ **សម្តេចធិបតី** បានគូសបញ្ជាក់ថា **ការស្តារទំនុកចិត្តនៃប្រព័ន្ធសកលឡើងវិញ** ជាប្រធានបទមួយដ៏លំបាកដែលឆ្លុះបញ្ចាំងពីការទទួលខុសត្រូវដ៏ធំរបស់មេដឹកនាំពិភពលោក មិនថានៅក្នុងឆាកពិភព [illegible] វិស័យ

ឯកជន វិស័យសិក្សាធិការ ឬអង្គការក្រៅរដ្ឋាភិបាលនោះឡើយ។ **សម្តេចធិបតី** បានចែករំលែកចំណុចសំខាន់ចំនួនពីរ **ទីមួយ គឺភាពចាំបាច់ដែលត្រូវធ្វើឱ្យពិភពលោកមានសន្តិភាព និងទីពីរ គឺត្រូវធ្វើឱ្យសេដ្ឋកិច្ចពិភពលោកងើបឡើងវិញដើម្បីផ្តល់ផលប្រយោជន៍ឱ្យប្រជាជនគ្រប់ៗគ្នា។ ប្រមុខរាជរដ្ឋាភិបាលកម្ពុជា** ក៏បានកត់សម្គាល់អំពីផលវិបាកនៃការធ្វើពាណិជ្ជកម្មអន្តរជាតិដោយសារការប្រកួតប្រជែងភូមិសាស្ត្រនយោបាយ និងការដាក់ចេញវិធានការក្រោមហេតុផលសន្តិសុខ។

<u>**ជំនួបជាមួយមេដឹកនាំប្រទេស ឥស្សរជនបរទេស និងថ្នាក់ដឹកនាំអង្គការអន្តរជាតិ៖**</u> ក្នុងអំឡុងពេលស្នាក់នៅទីក្រុងដាវ៉ូស នោះដែរ **សម្តេចធិបតី** បានជួបពិភាក្សាដាច់ដោយឡែកជាមួយ ឯកឧត្តម Tony Blair អតីតនាយករដ្ឋមន្ត្រីអង់គ្លេស និងជាប្រធានប្រតិបត្តិវិទ្យាស្ថានបម្រែបម្រួលសកល ឯកឧត្តម John Kerry អតីតរដ្ឋមន្ត្រីការបរទេស និងជាបេសកជនពិសេសរបស់ប្រធានាធិបតីអាម៉េរិកទទួលបន្ទុកកិច្ចការអាកាសធាតុ នាយករដ្ឋមន្ត្រីវៀតណាម នាយករដ្ឋមន្ត្រីថៃ រដ្ឋមន្ត្រីក្រសួងបរិវត្តកម្មឌីជីថលជប៉ុន ស្ថាបនិកនិងជាប្រធានវេទិកាសេដ្ឋកិច្ចពិភពលោក អគ្គលេខាធិការអង្គការសុខភាពពិភពលោក (WHO) ប្រធានរបៀបវារៈតំបន់អាស៊ីប៉ាស៊ីហ្វិក និងជាសមាជិកគណៈកម្មាធិការប្រតិបត្តិនៃវេទិកាសេដ្ឋកិច្ចពិភពលោក អគ្គលេខាធិការអង្គការសម្រាប់កិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច (OECD) អគ្គនាយកនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WIPO) និងអ្នកគ្រប់គ្រងនៃទីភ្នាក់ងារ USAID។ ក្នុងជំនួបទាំងនោះ **សម្តេចធិបតី** និងដៃគូសន្ទនា បានពិភាក្សានិងផ្លាស់ប្តូរយោបល់គ្នាយ៉ាងស៊ីជម្រៅ អំពីកិច្ចសហប្រតិបត្តិការទ្វេភាគី និងការរួមចំណែកដោះស្រាយបញ្ហាតំបន់ និងពិភពលោក។

<u>**ជំនួបជាមួយបណ្តាធុរជនឈានមុខ៖**</u> **សម្តេចធិបតី** ក៏បានទទួលជួបពិភាក្សាដាច់ដោយឡែកជាមួយថ្នាក់ដឹកនាំក្រុមហ៊ុនអន្តរជាតិចំនួន ៩ ក្នុងនោះមានដូចជា ក្រុមហ៊ុន Hawkeye 360 Inc (អភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានលំហភូមិសាស្ត្រ) ក្រុមហ៊ុន Shenzhen Power Solution (វិនិយោគផលិតផលអំពូលសូឡាមានតម្លៃសមរម្យលំដាប់ពិភពលោក) ក្រុមហ៊ុន Trip.com (ជាវេបសាយធ្វើដំណើរមួយឈានមុខលើពិភពលោក) ក្រុមហ៊ុន Wilmar International (ធុរកិច្ចលើវិស័យកសិកម្ម) ក្រុមហ៊ុន Grab (វិនិយោគបច្ចេកវិទ្យាទូរសព្ទចល័តផ្តល់សេវាកម្មដឹកជញ្ជូនអាហារនិងការទូទាត់តាមប្រព័ន្ធឌីជីថល) និងបណ្តាក្រុមហ៊ុនមួយចំនួនទៀត។ ក្នុងជំនួបនោះ ថ្នាក់ដឹកនាំក្រុមហ៊ុននីមួយៗ បានជម្រាប **សម្តេចធិបតី** អំពីសក្តានុពលវិនិយោគ ដោយបង្ហាញបំណងពង្រីកការវិនិយោគដែលមានស្រាប់នៅកម្ពុជា និងសិក្សាអំពីលទ្ធភាពបោះទុនវិនិយោគថ្មីបន្ថែមទៀត។ **សម្តេចធិបតី** បានចូលរួមអបអរសាទរចំពោះវឌ្ឍនភាពរបស់ក្រុមហ៊ុននីមួយៗ និងបានគូសបញ្ជាក់ថា ជាមួយនឹងកត្តាសុខសន្តិភាព ស្ថិរភាពនយោបាយ និងភាពអំណោយផលនៃច្បាប់វិនិយោគ ក៏ដូចជាគោលការណ៍អនុគ្រោះផ្សេងៗ រាជរដ្ឋាភិបាលកម្ពុជាស្វាគមន៍ និងត្រៀមលក្ខណៈផ្តល់ការគាំទ្រគ្រប់ពេលវេលា។

**ក្នុងស្មារតីសាមគ្គីភាពជាតិ**!

ទោះបីមានកាពមមាញឹកដូចបានបញ្ជាក់ខាងលើនេះក៏ដោយ **សម្តេចធិបតី** និង **លោកជំទាវបណ្ឌិត** បានជួបសំណេះសំណាលជាមួយបងប្អូនសហគមន៍ខ្មែររស់នៅទ្វីបអឺរ៉ុបប្រមាណជាង ២ ពាន់នាក់។ ជាមួយគ្នានេះ **លោកជំទាវបណ្ឌិត** ក៏បានបន្តជួបសំណេះសំណាលជាមួយនិស្សិតខ្មែរនៅអឺរ៉ុបប្រមាណ ៣០០ នាក់ទៀត

ផងដែរ។ គោលបំណងនៃជំនួបនេះ ក៏មិនខុសពីគន្លងដ៏ឧត្តុង្គឧត្តមដែល **សម្តេចតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រីធ្លាប់បានធ្វើនោះដែរ គឺដើម្បីស្វែងយល់ពីសុខទុក្ខ និងតម្រូវការចាំបាច់នានារបស់ពលរដ្ឋខ្មែរនៅតំបន់អឺរ៉ុប ព្រមទាំងផ្តល់ព័ត៌មានអំពីស្ថានភាពជាទូទៅនៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមនៅមាតុប្រទេស ការវិវត្តជាសកល គោលបំណងសំខាន់នៃដំណើរទស្សនកិច្ចនៅប្រទេសបារាំង និងបេសកកម្មនៅប្រទេសស្វីស។ ពលរដ្ឋ និងនិស្សិតខ្មែរ បានសម្តែងក្តីរំភើបរីករាយ ដែលមានឱកាសបានជួប **សម្តេចធិបតី** និង**លោកជំទាវបណ្ឌិត** ព្រមទាំងបង្ហាញអំណរសាទរយ៉ាងក្លៀវក្លា និងការជឿជាក់យ៉ាងពេញទំហឹងចំពោះ **សម្តេចធិបតី** ក្នុងការដឹកនាំរាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៧ នៃរដ្ឋសភា បន្តវេនពីរាជរដ្ឋាភិបាលក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោ ហ៊ុន សែន**។

ជោគជ័យដ៏ធំធេងគួរជាទីមោទនៈដែលកម្ពុជាទទួលបានពីបេសកកម្មរបស់ **សម្តេចធិបតី** នៅប្រទេសបារាំង និងប្រទេសស្វីស ពីថ្ងៃទី១៣ ដល់ ថ្ងៃទី២០ ខែមករា ឆ្នាំ២០២៤ នេះ មិនមែនកើតឡើងដោយចៃដន្យនោះទេ។ លទ្ធផលនេះកើតចេញពីកត្តារួមផ្សំគ្នារវាងស្នាដៃដែលសាងឡើងដោយមេដឹកនាំ **ជំនាន់ទី១** គឺ **សម្តេចតេជោ ហ៊ុន សែន** និងសមត្ថភាពដ៏ប៉ិនប្រសប់របស់មេដឹកនាំ **ជំនាន់ទី២** គឺ **សម្តេចធិបតី ហ៊ុន ម៉ាណែត** ពោលគឺ **មេដឹកនាំចាស់ពូកែសាងស្នាដៃ អ្នកដឹកនាំថ្មីពូកែថែរក្សា ពូនជ្រុំ និងពង្រីកបន្ថែម**។ ចំណុចខ្លាំងនេះហើយដែលបង្កើតបានជាចលករលើកស្ទួយកិត្យានុភាព និងមោទនភាពជាតិខ្មែរឱ្យខ្ពស់ត្រដែតលើឆាកអន្តរជាតិ និងបានផ្តល់ភាពស័ក្តិសមសម្រាប់ **ប្រធានាធិបតី នាយករដ្ឋមន្ត្រី** ក៏ដូចជា **ប្រធានព្រឹទ្ធសភា** និង**ប្រធានរដ្ឋសភាបារាំង** ក្នុងការទទួលបដិសណ្ឋារកិច្ចប្រមុខដឹកនាំកម្ពុជាប្រកបដោយកិត្តិយសលើកម្រាលព្រំក្រហមនៅលើទឹកដីនៃទ្វីបអឺរ៉ុប។

ថ្ងៃសៅរ៍ ១០កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមករា ឆ្នាំ២០២៤